ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 15-Jun-2015, 15:38
CMS/CFO: Sann Rada

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber
Chambre de la Cour supreme

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007/ECCC/SC

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រ៊ឹម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សេរីវុឌ្ឍ**
**ចៅក្រម Agniezska KLONOWIECKAMILART**
**ចៅក្រម មុំ មុន្នីចរិយា**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** **ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៥**
**ភាសាដើម៖** **ខ្មែរ/អង់គ្លេស**
**ចំណាត់ថ្នាក់ឯកសារ៖** **សាធារណៈ**

# សេចក្តីសម្រេចស្នើឱ្យដាក់សារណាស្តីពីកិច្ចស៊ើបសួរបន្ថែម

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីជនជាប់ចោទ នួន ជា**
សុន អរុណ
Victor KOPPE

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ
Marie GUIRAUD

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

01106925



**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" និង "អ.វ.ត.ក"),

**រំលឹកឡើងវិញ** នូវសេចក្តីសម្រេចចាត់តាំង ដែលក្នុងនោះអង្គជំនុំជម្រះតុលាការកំពូល បានសម្រេចបើកកិច្ចស៊ើបសួរបន្ថែម ដោយអនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ("កិច្ចស៊ើបសួរបន្ថែម") [1] ដោយបានសម្រេចចាត់តាំងចៅក្រម **ម៉ុង មុន្នីចរិយា** និងចៅក្រម **Chandra Nihal JAYASINGHE** ជាចៅក្រមតំណាង[2],

**រំលឹកឡើងវិញ**ថា គោលបំណងចម្បងនៃកិច្ចស៊ើបសួរនេះ គឺដើម្បីធ្វើការទំនាក់ទំនងដោយផ្ទាល់ជាមួយនឹង **Robert Thomas Fitzgibbon LEMKIN** ("សាក្សី") និង **ថេត សម្បត្តិ** ក្នុងការវាយតម្លៃថាតើឈុតខ្សែវីដេអូដែលស្ថិតក្នុងដៃរបស់ពួកគាត់ទាំងពីរនោះ អាចប្រគល់ជូនអង្គជំនុំជម្រះក្នុងពេលវេលាសមស្របបានដែរ ឬយ៉ាងណា និងបញ្ជាក់បានថាតើ មានព័ត៌មានជាក់លាក់អ្វីខ្លះ ដែលត្រូវពិនិត្យមើលនោះ[3]។

**រំលឹកឡើងវិញ**ថា សាក្សី ត្រូវបានស្តាប់ចម្លើយនៅចំពោះមុខចៅក្រមតំណាងនៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៥[4],

**រំលឹកឡើងវិញ**ថា សាក្សីប្រកាស *ក្នុងចំណោមនោះ*ថា: (១) ការអះអាងពីមុនរបស់គាត់ នៅក្នុងអ៊ីម៉ែលមួយដែលបានផ្ញើទៅកាន់មេធាវីការពារក្តី នួន ជា គឺលោក Victor Koppe,[5] ថា គាត់មាន"ភស្តុតាងជាច្រើនស្តីអំពីរបៀបវារៈរបស់ រស់ ញឹម" ជាចម្បង គឺបានផ្អែកទៅលើព័ត៌មានដែលទទួលបានក្នុងពេលកិច្ចសម្ភាសន៍ជាមួយមនុស្សបួននាក់[6], (២) គាត់ មានឆន្ទៈចង់បង្ហាញអត្តសញ្ញាណរបស់អ្នកទាំងនោះ និងបាន

[1] វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក វិសោធនកម្មលើកទី ៩ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥ ("វិធានផ្ទៃក្នុង")។

[2] សេចក្តីសម្រេចបណ្តោះអាសន្នលើផ្នែកខ្លះនៃសំណើទីមួយរបស់ នួន ជា សុំទទួលយក និងពិចារណា លើភស្តុតាងបន្ថែមនៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខនៃសំណុំរឿង ០០២/០១ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥, ឯកសារលេខ F2/4/3 ("សេចក្តីសម្រេចចាត់តាំង") កថាខណ្ឌ ២៥ ដល់ ២៦។

[3] សេចក្តីសម្រេចចាត់តាំង កថាខណ្ឌ ២១ ដល់ ២៦។

[4] កំណត់ហេតុស្តាប់ចម្លើយសាក្សី–Robert T.F. Lemkin, ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥, ឯកសារលេខ F2/4/3/1, ("កំណត់ហេតុស្តាប់ចម្លើយសាក្សី Lemkin")។

[5] សំណើសុំឱ្យទទួលយកភស្តុតាងថ្មី កោះហៅ Rob Lemkin និងការបើកកិច្ចស៊ើបសួរ ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣, ឯកសារលេខ E294, កថាខណ្ឌ ២។

[6] កំណត់ហេតុស្តាប់ចម្លើយសាក្សី Lemkin កថាខណ្ឌ ចម្លើយ ៣៤។

ប្រគល់ជូនឈុតខ្សែវីដេអូទាក់ទងនឹងបុគ្គលទាំងបួននាក់នោះមកឱ្យតុលាការ ដរាបណា សហនាយកផលិតករ គឺលោក **ថេត សម្បត្តិ** យល់ព្រមជាមុនសិន[7] និង (៣) គាត់ ត្រៀមខ្លួនក្នុងការផ្តល់ជូនតុលាការនូវកំណត់ហេតុពុំទាន់បានចេញផ្សាយរបស់គាត់ ដែលសង្ខេបនូវខ្លឹមសារនៃកិច្ចសម្ភាសន៍ជាមួយអ្នកទាំងបួនរូបនោះ ("កំណត់ហេតុ")[8],

**រំលឹកឡើងវិញ**ថា **ថេត សម្បត្តិ** ពុំបានយល់ព្រមក្នុងការចេញផ្សាយឈុតខ្សែវីដេអូនេះទេ ដោយមូលហេតុថា ថ្មីៗនេះ អ្នកទាំងបួននាក់នោះ បានស្នើសុំគាត់មិនឱ្យប្រគល់ឈុតខ្សែវីដេអូ ឬប្រតិចារិកណាមួយទៅភាគីដទៃទៀយ និងថា ការចេញផ្សាយឈុតខ្សែវីដេអូនេះ នឹងអាចប៉ះពាល់ដល់សុវត្ថិភាពរបស់គាត់ និងអ្នកដទៃទៀត[9],

**កត់សម្គាល់ឃើញ**ថា នៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៥ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលបានទទួលឯកសារនេះ[10] ពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ("WESU") ដែលសាក្សីបានផ្ញើមក[11],

**កត់សម្គាល់ឃើញ**ថា សាក្សី បានយល់ព្រមផ្តល់ជូន អ.វ.ត.ក នូវកំណត់ហេតុដែលត្រូវធ្វើចំណាត់ថ្នាក់ជាសម្ងាត់ និងថា បើទោះបីជាមានការអះអាងបញ្ជាក់ថា ឈ្មោះរបស់អ្នកទាំងបួននាក់ ដែលនិយាយសំដៅទៅលើនោះ នឹងត្រូវបានចាត់ថ្នាក់ជាសម្ងាត់បំផុតក៏ដោយ ក៏សាក្សីនៅតែបដិសេធក្នុងការបង្ហាញឈ្មោះទាំងអ្នកទាំងនោះ ពីព្រោះបើបង្ហាញវិញនោះ នឹងផ្ទុយទៅនឹងសេចក្តីបង្គាប់របស់ **ថេត សម្បត្តិ**[12],

**ពិចារណាឃើញ**ថា មុនពេលធ្វើការសម្រេចចុងក្រោយរបស់ខ្លួនទៅលើបញ្ហា ថាតើ ត្រូវបន្តកិច្ចស៊ើបសួរបន្ថែមទៀតដោយរបៀបណានោះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជាការសមស្របក្នុងការផ្តល់ឱកាសឱ្យភាគីធ្វើការបង្ហាញលើបញ្ហានេះ,

---

[7] កំណត់ហេតុស្តាប់ចម្លើយសាក្សី Lemkin កថាខណ្ឌ ចម្លើយ ៣៦។

[8] កំណត់ហេតុស្តាប់ចម្លើយសាក្សី Lemkin កថាខណ្ឌ ចម្លើយ ៦, ៣៦ និង ៣៨។

[9] អនុស្សរណៈរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ មានចំណងជើងថា "របាយការណ៍តបទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ឯកសារលេខ F2/4/3" និង ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥, ឯកសារលេខ F2/4/3/2 (សម្ងាត់)។

[10] ឧបសម្ព័ន្ធ-កំណត់ហេតុរបស់ Robert Lemkin ស្តីពីរបៀបវារៈនយោបាយរបស់ វស់ ញឹម ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥, ឯកសារលេខ F2/4/3/3.1 (សម្ងាត់)។

[11] អ៊ីម៉ែលអេឡិចត្រូនិចផ្ញើពីអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ទៅកាន់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល មានចំណងជើងថា "សម្ងាត់ - កំណត់ហេតុពុំទាន់បានផ្សព្វផ្សាយ" នៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៥ វេលាម៉ោង ០៩ និង ១០ នាទីព្រឹក ដាក់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។

[12] អ៊ីម៉ែលអេឡិចត្រូនិចផ្ញើពីអង្គភាពគាំពារសាក្សីនិងអ្នកជំនាញមានចំណងជើងថា "សម្ងាត់-កំណត់ហេតុពុំទាន់បានផ្សព្វផ្សាយ" ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៥ នៅម៉ោង ០៨ និង ២០ នាទីល្ងាច នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។

សំណុំរឿងលេខៈ ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក

ឯកសារលេខ F2/4/3/3

## អាស្រ័យហេតុនេះ៖

**ស្នើឱ្យ នួន ជា** ដាក់សារណាជាលាយលក្ខណ៍អក្សរត្រឹមថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៥ ដោះស្រាយលើបញ្ហាដូចខាងតទៅ៖ (១) ថាតើ កំណត់ហេតុនេះ គប្បីត្រូវបានទទួលយកជាភស្តុតាង ដែរ ឬយ៉ាងណា (២) ថាតើ មានចំណាត់ការណាបន្ថែមទៀត គប្បីធ្វើឡើងដោយចៅក្រមតំណាង ឬអង្គជំនុំជម្រះ ដែរ ឬយ៉ាងណា ទាក់ទងនឹងព័ត៌មានដែលបានមកពីកិច្ចសើុបសួរបន្ថែមនេះ។

**ស្នើឱ្យ** ភាគីដទៃទៀតដាក់សារណាតបទៅនឹងសារណារបស់ នួន ជា ត្រឹមថ្ងៃ ព្រហស្បត៍ ទី ២៣ ខែ កក្កដា ឆ្នាំ ២០១៥។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ីម**